**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ២២៤០ សស/ស

**ជម្រាបជូន**

**ឯកឧត្តម អភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាព**
**រដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសវៀតណាម**

**កម្មវត្ថុ** ៖ ស្តីពីការពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យការចេញចូលឆ្លងកាត់ព្រំដែន ដើម្បីបង្ការ ទប់ស្កាត់ការឆ្លងរាតត្បាតនៃជំងឺកូវីដ១៩ នៅកម្ពុជា។

**យោង** ៖ សេចក្តីសម្រេចលេខ ២៩ សសរ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩(COVID-19)។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា នាពេលថ្មីៗនេះនៅតំបន់ខ្លះនៃប្រទេសវៀតណាមមានការឆ្លងរីករាលដាលនូវជំងឺកូវីដ១៩ ហើយអាជ្ញាធរវៀតណាមបាននិងកំពុងចាត់វិធានការបិទការចេញចូលនៅតំបន់ដែលមានការឆ្លងជំងឺកូវីដ១៩នេះផងដែរ។ ក្នុងស្មារតីនេះ ដើម្បីចូលរួមសហការក្នុងការបង្ការ ទប់ស្កាត់ការឆ្លងរាតត្បាតជំងឺកូវីដ១៩នៅកម្ពុជា ខ្ញុំសូមណែនាំដល់ **ឯកឧត្តម អភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត** ត្រូវយកចិត្តទុកដាក់លើការងារដូចខាងក្រោម៖

- ត្រូវណែនាំដល់សមត្ថកិច្ចប្រចាំច្រកទ្វារព្រំដែនឲ្យពង្រឹងការគ្រប់គ្រង និងការត្រួតពិនិត្យមធ្យោបាយដឹកជញ្ជូន និងអ្នកដំណើរដែលដឹកជញ្ជូនទំនិញចេញចូលឆ្លងកាត់ព្រំដែនកម្ពុជា-វៀតណាម ស្របតាមវិធានបច្ចេកទេសដែលកំណត់ដោយក្រសួងសុខាភិបាលឲ្យបានម៉ត់ចត់បំផុត
- ត្រូវចាត់វិធានការឲ្យបានតឹងរ៉ឹង និងម៉ឺងម៉ាត់ ដើម្បីបង្ការ ទប់ស្កាត់កុំឲ្យមានការលួចឆ្លងដែនដោយខុសច្បាប់ចេញចូលឆ្លងកាត់ព្រំដែនតាមច្រករបៀងនានាក្នុងភូមិសាស្ត្ររបស់ខ្លួន
- បន្តជំរុញការអប់រំណែនាំ និងផ្សព្វផ្សាយដល់សាធារណជន និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសប្រជាពលរដ្ឋរស់នៅតាមតំបន់ព្រំដែន ឲ្យបង្កើនការប្រុងប្រយ័ត្នការពារខ្លួនស្របតាមការណែនាំនានារបស់ក្រសួងសុខាភិបាល ដើម្បីកុំឲ្យមានវីរុសកូវីដ១៩ ឆ្លងមកលើបុគ្គល និងសហគមន៍មូលដ្ឋាននៅកម្ពុជា។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។
សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានពីខ្ញុំ។

ថ្ងៃ សុក្រ ១១កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ២០២០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- ឯកសារ-កាលប្បវត្តិ